**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# អន្លង់ថ្មបាំង

## រយៈពេល ៣ ឆ្នាំ (២០២០ - ២០២២)

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ | អន្លង់ថ្មបាំង |
| ភូមិ | ៖ | ខាំជាន់ (ចំណុចខេ) |
| សង្កាត់ | ៖ | សាមគ្គី |
| ក្រុង | ៖ | ស្ទឹងត្រែង |
| ខេត្ត | ៖ | ស្ទឹងត្រែង |

ព្រះ[illegible]ណា[illegible]ម្ពុ

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# អន្លង់ថ្មបាំង
# រយៈពេល ៣ ឆ្នាំ (២០២០- ២០២២)

| | |
|---|---|
| សហគមន៍នេសាទ | ៖ អន្លង់ថ្មបាំង |
| ភូមិ | ៖ ខាំផាន់ (ចំនុចខេ) |
| សង្កាត់ | ៖ សាមគ្គី |
| ក្រុង | ៖ ស្ទឹងត្រែង |
| ខេត្ត | ៖ ស្ទឹងត្រែង |

ខែមករា ឆ្នាំ២០១៩

# មាតិកា


**១.ស្ថានភាពទូទៅ** ........ ១

**២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម** ........ ២

ក.ប្រជាពលរដ្ឋ ........ ២

ខ.មុខរបរ ........ ២

**៣.កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........ ២

ក.ទីតាំង ........ ២

ខ. ដែននេសាទ ........ ២

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ ៤

ឃ.ធនធានជលផល ........ ៤

ឃ.១.ប្រភេទត្រី៖ ........ ៤

ឃ.២.ប្រភេទវារីសត្វ៖ ........ ៤

ឃ.៣.ប្រភេទសត្វបក្សី ........ ៤

ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖ ........ ៤

**៤.ការធ្វើនេសាទ** ........ ៥

ក.អ្នកនេសាទ ........ ៥

ខ.ឧបករណ៍នេសាទ ........ ៥

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........ ៦

**៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ........ ៦

ក.ទស្សនវិស័យ ........ ៦

ខ. គោលបំណងរួម ........ ៦

គ.គោលបំណងជាក់លាក់ ........ ៦

ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ៧

ឃ.១.ធនធានជលផល និងអេកូឡូស៊ី ........ ៧

ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ ៧

ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ........ ៧

ឃ.១.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ........ ៨

ឃ.១.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក ........ ៨

ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ ........ ៨

ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល ........ ៨

ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ ៩

ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ........ ៩

ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ ........ ៩
ឃ.៣. ការងារគ្រប់គ្រង ........ ១០
ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ........ ១០
ឃ.៣.២.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ ........ ១១
ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ........ ១១
ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ១២
ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........ ១២
ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........ ១៣
ការតាមដាន ត្រួពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោម៖ ........ ១៣
ច.យុទ្ធសាស្រ្ត ........ ១៣
**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អន្លង់ថ្មបាំង រយៈពេល៣ឆ្នាំ** ( **២០២០ ដល់ ២០២២** ) ........ ១៥
**តារាងកម្មវិធីការងាររយៈពេល៣ឆ្នាំ**( **២០២០ - ២០២២** ) ........ ២១

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១.ស្ថានភាពទូទៅ

សហគមន៍នេសាទអន្លង់ថ្មបាំង ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៣ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី២ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ រយៈពេល ៣ឆ្នាំ គឺចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១។ សហគមន៍នេសាទនេះមានទីតាំងស្ថិតនៅក្នុងភូមិខាំផាន់ (ចំនុចខេ) សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ដែលមានសមាជិកសរុបចំនួន ៣៩០នាក់ ស្ត្រី២០១នាក់ ស្មើនឹង១៥០គ្រួសារ។ សហគមន៍នេសាទអន្លង់ថ្មបាំង ត្រូវបានក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។

បន្ទាប់ពីបានបោះឆ្នោតជ្រើសរើសគណៈកម្មការរួចមកសហគមន៍នេសាទ បានអនុវត្តសកម្មភាពសំខាន់ៗ មានដូចជាការរៀបចំបញ្ជីឈ្មោះ និងរចនាសម្ព័ន្ធរបស់គណៈកម្មការនេសាទថ្មី ធ្វើបច្ចុប្បន្នភាព និងរៀបចំបញ្ជីឈ្មោះសមាជិក រៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ រៀបចំអន្លង់អភិរក្ស រៀបចំក្រុមល្បាត និងចុះល្បាតជាប្រចាំ ព្រមទាំងចូលរួមប្រជុំ និងចូលរួមវគ្គបណ្តុះបណ្តាលសិក្ខាសាលាផ្សេងៗ និងរៀបចំធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ផងដែរ។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនៅជួបប្រទះបញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងដូចជាបញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផល និងអេកូឡូស៊ី រួមមានបាត់បង់ព្រៃលិចទឹកដដយសារកំលាំងទឹកហូរខ្លាំងធ្វើអោយរលំអស់ជាច្រើន ត្រីថយចុះគ្រប់ប្រភេទការនេសាទនៅរដូវត្រីពងកូន បាក់ច្រាំងមាត់ទន្លេ និងកំណើនអ្នកនេសាទក្នុងសហគមន៍ និងមកពីខាងក្រៅ អាកាសធាតុក្តៅខ្លាំង ខ្វះទឹកភ្លៀងសម្រាប់បង្ករបង្កើនផលដំណាំ។

បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋរួមមាន ប្រជាពលរដ្ឋខ្វះមុខរបរចិញ្ចឹមជីវិត ចំនួនប្រជាពលរដ្ឋក្នុងភូមិកើនឡើង ប្រជាជនចំណាកស្រុកច្រើន ខ្វះប្រភពទឹកធ្វើស្រែ ខ្វះចំណេះដឹងនិងជំនាញបច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំ តម្លៃផលិតផលមិនស្ថិតស្ថេរ ភ្លៀងធ្លាក់មិនទៀងទាត់(ខ្វះទឹកភ្លៀង)។

បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រងរួមមាន ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ (ប្រើប្រាស់ឧបករណ៍ឆក់ និងសារជាតិពុល គប់គ្រាប់នៅអន្លង់អភិរក្ស) ប្រជាពលរដ្ឋមិនហ៊ានរាយការណ៍ពេលឃើញបទល្មើស កិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធមិនទាន់រលូន មានការឃុបឃិតជាមួយជនល្មើស មិនសូវមានការលើកទឹកចិត្តដល់គណកម្មការសហគមន៍នេសាទ ប្រជាពលរដ្ឋមិនយល់ពីសារៈប្រយោជន៍នៃសហគមន៍នេសាទ ជនល្មើសមិនខ្លាចគណៈកម្មការសហគមន៍ ខ្វះមធ្យោបាយចុះល្បាត និងថវិកា គ្មានទីស្នាក់ការសហគមន៍សម្រាប់ប្រតិបត្តិការ គណៈកម្មការសហគមន៍នេសាទពុំទាន់ស្គាល់ពីតួនាទីរបស់ខ្លួន ហើយគណៈកម្មការសហគមន៍នេសាទ និងប្រជាជនមិនទាន់យល់ពីច្បាប់ជលផល លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ។

## ២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋក្នុងភូមិខាំផាន់ (ចំនុចខេ) សរុប៥២០នាក់ ស្ត្រី២៦៨នាក់ ស្មើ ១៥០គ្រួសារ (សរុប១,៦៩៣នាក់ ស្រី៨៧៣ ស្មើ៤១៦គ្រួសារ) ក្នុងនោះមានជនជាតិខ្មែរចំនួន៨៨,៤៧% និងអ៊ីស្លាម១១,៥៣% ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធមាន៨៨,៤៧% និង១១,៥៣% កាន់សាសនាអ៊ីស្លាម និងកាតូលិក។

ប្រជាពលរដ្ឋក្នុងភូមិ មានស្ថានភាពដូចខាងក្រោមៈ

- ចំនួនស្ត្រីជាមេគ្រួសារ/ស្ត្រីមេម៉ាយមាន ១៥នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន០២នាក់ ស្ត្រី០១នាក់
- ចំនួនចាស់ជរាមាន០១នាក់ ស្ត្រី០០នាក់
- កម្រិតសិក្សាអប់រំមាន អ្នកមិនចេះអក្សរមានចំនួន៣៩៤នាក់ ស្ត្រី១៩៦នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន ១១៨នាក់ ស្ត្រី៦៨នាក់ កម្រិតអនុវិទ្យាល័យចំនួន០៨នាក់ ស្ត្រី ០៤នាក់។

### ខ.មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានៈ

- អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួន ៧០គ្រួសារ ត្រូវនឹង ៩១%
- អ្នកធ្វើស្រែចំនួន៧០គ្រួសារ ដែលមានទំហំដីចំនួនសរុប ១០៥ ហិកតា
- ធ្វើចំការចំនួន១៣០គ្រួសារដែលមានទំហំដីចំនួនសរុប២៦០ហិកតា (ស្រូវ.ពោត.ដំឡូង.សណ្តែក.ថ្នាំជក់.ល្ង និងត្រសក់ តាមរដូវកាល)
- លក់ដូរជាអាជីពចំនួន១០ គ្រួសារ
- ដាំបន្លែ ៧០គ្រួសារ
- កែច្នៃផលនេសាទជាលក្ខណៈគ្រួសារចំនួន៦០ គ្រួសារ ក្នុងនោះរួមមានប្រហុក ផ្អក ត្រីប្រៃ។ មួយគ្រួសារអាចផលិតបានពី១០ គីឡូក្រាមទៅ ៣០គីឡូក្រាមក្នុង១ឆ្នាំ

## ៣ កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

### ក.ទីតាំង

កន្លែងនេសាទសហគមន៍អន្លង់ថ្មបាំង ជាដែននេសាទសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍អន្លង់ថ្មបាំង មានទំហំ ១.២៩៩ ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

**មានព្រំប្រទល់ ៖**

-ខាងជើងទល់នឹង សហគមន៍នេសាទភូមិកោះកី ឃុំកោះស្នែង ស្រុកបុរីអូរស្វាយសែនជ័យ

-ខាងត្បូងទល់នឹង សហគមន៍នេសាទថ្មតាគុ ភូមិខាំផាន់ សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង

-ខាងកើតទល់នឹង ភូមិខាំផាន់(ចំនុចខេ) សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

-ខាងលិចទល់នឹង សហគមន៍នេសាទភូមិកោះស្នែង ឃុំកោះស្នែង ស្រុកបុរីអូរស្វាយសែនជ័យ។

### ខ.ដែននេសាទ

កន្លែងសហគមន៍នេសាទអន្លង់ថ្មបាំង មានវិសាលភាពនៅក្នុងទន្លេមេគង្គ ហើយមានអូរចំនួន៨ កោះចំនួន៣ ប្រឡាយចំនួន១២ និងអន្លង់ចំនួន៥ ។

ខ.១.ទន្លេ

| ឈ្មោះទន្លេ | ប្រវែង (ម) | រដូវនេសាទ |
|---|---|---|
| ទន្លេមេគង្គ | ៧.២០០ | ពេញមួយឆ្នាំ |

ខ.២.អូរ

| ឈ្មោះអូរ | ប្រវែង (ម) | រដូវនេសាទ |
|---|---|---|
| អូរក្របៅធំ | ២០.០០០ | ខែសីហា ដល់ខែវិច្ឆិកា |
| អូរក្របៅតូច | ១០.០០០ | ខែសីហា ដល់ខែវិច្ឆិកា |
| អូរឈើទាល | ៥០០ | ខែសីហា ដល់ខែវិច្ឆិកា |
| អូរសំរោង(អូរទីនឹង) | ១.៥០០ | ខែសីហា ដល់ខែវិច្ឆិកា |
| អូរតាឌី | ២០០ | ខែសីហា ដល់ខែវិច្ឆិកា |
| អូរឃេ | ៥០០ | ខែសីហា ដល់ខែវិច្ឆិកា |
| អូរម៉មកើត | ១.០០០ | ខែសីហា ដល់ខែវិច្ឆិកា |
| អូរកំបោ | ៣០.០០០ | ខែសីហា ដល់ខែវិច្ឆិកា |

ខ.៣.អន្លង់

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវវស្សា (ម៉ែត្រ) |
| អន្លង់សំរោងលើ | ៥០ × ៧០ | ៣.៥០០ | ៤២ | ៣០ |
| អន្លង់សំរោងក្រោម | ៥០ × ២០០ | ១.០០០ | ៦២ | ៤០ |
| អន្លង់តាឃឹម (គោល៤៦) | ៤៨០ × ១.០០០ | ៤៨.០០០ | ៤២ | ៣០ |
| អន្លង់ត្រីកេះ | ៧០ × ១០០ | ៧.០០០ | ៥២ | ៤០ |
| អន្លង់ថ្មបាំង | ៥០ × ៥០ | ២.៥០០ | ៦២ | ៥០ |

ខ.៤.ប្រឡាយ

| ឈ្មោះប្រឡាយ | ប្រវែង ( ម ) | រដូវនេសាទ |
|---|---|---|
| ប្រឡាយតាកុយ | ១០០ម | ខែសីហា ដល់ខែវិច្ឆិកា |
| ប្រឡាយតាដឿនចន្ថា | ១០០ម | ខែសីហា ដល់ខែវិច្ឆិកា |
| ប្រឡាយសេងឡុង | ៦០ម | ខែសីហា ដល់ខែវិច្ឆិកា |
| ប្រឡាយតាឃឿន | ៥០ម | ខែសីហា ដល់ខែវិច្ឆិកា |
| ប្រឡាយតាឃឹម | ៥០ម | ខែសីហា ដល់ខែវិច្ឆិកា |
| ប្រឡាយតាប៉ាន់ | ២០០ម | ខែសីហា ដល់ខែវិច្ឆិកា |
| ប្រឡាយតាណោវ | ២៥០ម | ខែសីហា ដល់ខែវិច្ឆិកា |



| | | |
|---|---|---|
| ប្រឡាយតាលុន | ១០០ម | ខែសីហា ដល់ខែវិច្ឆិកា |
| ប្រឡាយចន្ទី | ១៥០ម | ខែសីហា ដល់ខែវិច្ឆិកា |
| ប្រឡាយតាវ៉ា | ១៥០ម | ខែសីហា ដល់ខែវិច្ឆិកា |
| ប្រឡាយតាម៉ាន | ១០០ម | ខែសីហា ដល់ខែវិច្ឆិកា |
| ប្រឡាយតាគី | ១៥០ម | ខែសីហា ដល់ខែវិច្ឆិកា |

ខ.៥.កោះ

| ឈ្មោះកោះ | ទទឹង និងបណ្តោយ(ម៉ែត្រ) | ទំហំសរុប (ហិកតា) |
|---|---|---|
| កោះសំរោង | ៥០ម x ៥០០ម | ២,៥០ |
| កោះតាលឿង | ៣០ម x ៣០០ម | ០,៩០ |
| កោះហាន | ៥០០ម x ១.២០០ម | ៦០ |

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

សហគមន៍នេសាទអន្លង់ថ្មបាំង បានឯកភាពគ្នាយកតំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្សចំនួន១ អន្លង់ គឺអន្លង់តាឃឹម (គោល៤៦)។

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវវស្សា (ម៉ែត្រ) |
| អន្លង់តាឃឹម (គោល៤៦) | ៤៨០ × ១.០០០ | ៤៨.០០០ | ៤២ | ៣០ |

ឃ.ធនធានជលផល

ឃ.១.ប្រភេទត្រី

ត្រីរ៉ស់ ត្រីប្រា ត្រីឆ្ពោរ ត្រីឆ្លាំង ត្រីកែស ត្រីឆ្កោក ត្រីក្អែក ត្រីត្រសក់ ត្រីកញ្ចុះ ត្រីលិញ ត្រីរៀល ត្រីក្រាញ់ ត្រីចង្វារ ត្រីផ្ទោង ត្រីពោ ត្រីអាចម៍កុក ត្រីស្លឹកឫស្សី ត្រីកន្ទ្រប់ ត្រីក្លាំងហាយ ត្រីខ្នាន់ ត្រីសណ្តាយ ត្រីអណ្តែង ត្រីដំរី ត្រីតាអោន ត្រីក្រម៉ម ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្ទឹង ត្រីអំពិលទុំ ត្រីគ្រុំ ត្រីផ្កាស្មៅ ត្រីឈ្វាត ត្រីកញ្ជ្រូក ត្រីច្រកែង ត្រីកាហែ ត្រីក្រឹម ត្រីក្រឹមទន្សាយ ត្រីស្រកាវក្ដាម ត្រីឆ្ពិន ត្រីបណ្ដូលចេក ត្រីព្រលូង...។

ឃ.២.ប្រភេទវារីសត្វ

អណ្តើក ពស់ ខ្យងគូចស្រួច ខ្យងគូចទាល ខ្យងមាស (ខ្យងពណ៌លឿង) ក្ដាម អន្ទង់ ខ្ចៅគូចស្រួច ខ្ចៅគូចទាល កង្កែប ឈ្លើង គ្រុំ គ្រុំចំពុះទា លៀស ។ល។

ឃ.៣.ប្រភេទសត្វបក្សី

កុកស កុកក្រក មាន់ទឹក ប្រវឹក ទាព្រៃ រនាលខ្យង ក្អែកទឹក ក្អែកគោក...។

ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ

ដើមត្រែង ដើមអញ្ចោង ដើមរំចេក ដើមអណ្តែង ដើមត្រស់ ដើមរាំង ដើមល្វា ដើមឆ្មាទឹក ដើមក្ដុល ដើមជ្រៃ ដើមព្រីង ដើមញ ដើមព្រុះទឹក ដើមទន្លាត ដើមក្របៅ ដើមចេកទុំ ដើមពោ ដើមបន្លាឃ្លេ ។ល។

## ៤. ការធ្វើនេសាទ

### ក.អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ១៥៨នាក់ ស្រី ៧៨នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន៣០នាក់ ស្រី១០នាក់
- អ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៤គ្រួសារ/ថ្ងៃ ស្រី១នាក់។

### ខ.ឧបករណ៍នេសាទ

ឧបករណ៍នេសាទ និងទូកការណូតរបស់សមាជិកសហគមន៍នេសាទ អ្នកមិនចូលជាសមាជិក និងអ្នកនេសាទមកពីក្រៅសហគមន៍៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ / ប្រវែង | | | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | |
| មង | ម៉ែត្រ | ៩០គ្រួសារ× ១០០ម = ៩.០០០ម | ៣០គ្រួសារ× ១៥០ម= ៤.៥០០ម | ៤គ្រួសារ× ២០០ម =៨.០០០ម | ក្រឡា ២,៥០-០៧ ស.មជម្រៅ ០១-០៣ ម | ក្រឡា ២,៥០-០៧ ស.មជម្រៅ ០១-០៣ ម | ក្រឡា ២,៥០-០៧ ស.មជម្រៅ ០១-០៣ ម | ពេញមួយឆ្នាំ |
| មងខាវមុខបីរ | ម៉ែត្រ | ៧០គ្រួសារ× ៣៥ម = ២.៤៥០ម | គ្មាន | គ្មាន | ក្រឡា ២,៥០-០៧ ស.មជម្រៅ ០១-០៣ ម | ក្រឡា ២,៥០-០៧ ស.មជម្រៅ ០១-០៣ ម | គ្មាន | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ៩០គ្រួសារ× ១វង់=៩០វង់ | គ្មាន | គ្មាន | សំរុង៣.៥ ម - ៥.៥ម | គ្មាន | គ្មាន | ពេញមួយឆ្នាំ |
| សន្ទូច | ផ្លែ | ២៣គ្រួសារ× ១០០ផ្លែ =២.៣០០ផ្លែ | ៣០គ្រួសារ × ១០០ផ្លែ =៣០០ផ្លែ | ៤គ្រួសារ× ១០០ផ្លែ =៤០០ផ្លែ | ផ្លែលេខ ១២-០៥ | ផ្លែលេខ ១២-០៥ | ផ្លែលេខ ១២-០៥ | ពេញមួយឆ្នាំ |
| លប | គ្រឿង | ១៥គ្រួសារ× ៣គ្រឿង =៤៥គ្រឿង | គ្មាន | គ្មាន | មុខកាត់ ០,៣០ម បណ្តោយ ១,៥០ម | គ្មាន | គ្មាន | វស្សា |
| ចាន់ | គ្រឿង | ១៥គ្រួសារ× ៣គ្រឿង =៤៥គ្រឿង | គ្មាន | គ្មាន | ទំហំ៣០ - ៥០ស.ម ប្រវែង ១ម | គ្មាន | គ្មាន | វស្សា |

ប្រភេទទូកកាណូតរបស់សមាជិក

| ប្រភេទកាណូត | ចំនួន | | | ចំណុះ (គីឡូក្រាម) | | | កំលាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកអេរជាប់ម៉ាស៊ីន HONDA | ២០ | ៣០ | ៤ | ១៥០-៥០០ | ១៥០-៥០០ | ១៥០-៥០០ | ៥,៥ ៦,៥ ៨ ១៣ | ៥,៥ ៦,៥ ៨ ១៣ | ៦,៥ ៦ |
| ទូកអុំ ចែវ | ៥ | ០ | ០ | ៥០-១០០ | ៥០-១០០ | ៥០-១០០ | ០ | ០ | ០ |

គ.ការប៉ាន់ប្រមាណផលនេសាទចាប់ប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៧៤១,១៤ | ៩១៩,៩១ | ១.៦៦១,០១ |
| សរុប | ៧៤១,១៤ | ៩១៩,៩១ | ១.៦៦១,០១ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក.ទស្សនវិស័យ

សហគមន៍នេសាទអន្លង់ថ្មបាំង មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោម៖

- ធ្វើឱ្យត្រីមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ ។

### គ.គោលបំណងជាក់លាក់

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍មុខរបរចម្រុះ
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

### ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ឃ.១.ធនធានជលផល និងអេកូឡូស៊ី

### ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺគិតគូរអំពីដែននេសាទ ប្រភេទឧបករណ៍នេសាទ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ក្នុងទន្លេមេគង្គ | នេសាទពេញ១ឆ្នាំជាលក្ខណៈគ្រួសារ | មង | ក្រឡា២,៥០-០៧ស.មជម្រៅ ០១-០៣ ម | ១០០ម៉ែត្រ/គ្រួសារ | |
| | | ចាន់ | មុខកាត់ ៣០-៥០ស.ម ប្រវែង ១ម៉ែត្រ | ០៥គ្រឿង/គ្រួសារ | |
| | | លប | មុខកាត់ ០,៣០ម បណ្តោយ ១,៥០ម | ០៣គ្រឿង/គ្រួសារ | |
| | | សំណាញ់ | ជម្រៅ៣-៥ ម៉ែត្រ ក្រឡា០២-០៨ស.ម | ១វង់/គ្រួសារ | |
| | | សន្ទូច | ប្រវែង១០០ម៉ែត្រ លេខ១២-០៥ | ១០០ផ្លែ/គ្រួសារ | |
| | | មងខាវ | ឡា ២,៥០-០៧ស.មជម្រៅ ០១-០៣ ម | ១០០ម៉ែត្រ/គ្រួសារ | |
| -អូរក្របៅធំ<br>-អូរក្របៅតូច<br>-អូរឈើទាល<br>-អូរសំរោង | ខែ៨ - ខែ១២ | មង | ក្រឡា២,៥០-០៧ស.មជម្រៅ ០១-០៣ ម | ១០០ម៉ែត្រ/គ្រួសារ | |
| | | ចាន់ | មុខកាត់ ៣០-៥០ស.ម ប្រវែង ១ម៉ែត្រ | ០៥គ្រឿង/គ្រួសារ | |
| | | លប | មុខកាត់ ០,៣០ម បណ្តោយ ១,៥០ម | ០៣គ្រឿង/គ្រួសារ | |
| | | សំណាញ់ | ជម្រៅ៣-៥ ម៉ែត្រ ក្រឡា០២-០៨ស.ម | ១វង់/គ្រួសារ | |
| | | សន្ទូច | ប្រវែង១០០ម៉ែត្រ លេខ១២-០៥ | ១០០ផ្លែ/គ្រួសារ | |
| | | មងខាវ | ក្រឡា ២,៥០-០៧ស.មជម្រៅ ០១-០៣ ម | ១០០ម៉ែត្រ/គ្រួសារ | |

### ឃ.១.២ ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូដែនទីសហគមន៍នេសាទ

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូដែនទីសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ/ចំនួន | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកទទួលខុសត្រូវ | ពេលវេលា | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | បញ្ចប់ |
| កន្លែងនេសាទសហគមន៍អន្លង់ថ្មបាំង | បង្គោលព្រំធ្វើពីស៊ីម៉ងត៍ចំនួន៧បង្គោល | - ផលិតបង្គោលព្រំ<br>- រៀបចំក្រុមចុះបោះបង្គោលព្រំ<br>- ផ្សព្វផ្សាយជាសាធារណៈ | ៤.០០០ | -គណៈកម្មការ<br>-សមាជិក<br>-មេភូមិ | ២០២០ | ២០២២ |
| | ផ្ទាំងប៉ាណូដែនទីធ្វើពីដែក២ផ្ទាំង | - ផលិតផ្ទាំងប៉ាណូដែនទី<br>- ចុះបោះផ្ទាំងប៉ាណូដែនទី | ៥០០ | -គណៈកម្មការ<br>-សមាជិក<br>-មេភូមិ | ២០២០ | ២០២០ |
| | ស្លាកអប់រំ៣០ | ចុះបោះស្លាកក្នុងសហគមន៍ | ១២០ | គណៈកម្មការ | ២០២០ | ២០២០ |

### ឃ.១.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ | ទំហំ (ហិកតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់តាឃឹម (គោល៤៦) | ៤៨ ហិកតា | - ត្រីមេពូជ<br>- សត្វស្លាប<br>- ព្រៃលិចទឹក | - ផ្សព្វផ្សាយពីកន្លែងអភិរក្ស<br>- បោះទង់សំគាល់ព្រំតំបន់អភិរក្ស<br>- ដាក់ផ្លាកសញ្ញាចំនួន៣០<br>- ចុះល្បាតការពារជាប្រចាំ | ៤០០ | ២០២០ | ២០២២ |

### ឃ.១.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ (ហិកតា) | ប្រភេទព្រៃឈើការពារ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| ការថែរក្សានិងការពារព្រៃលិចទឹកក្នុងដែនសហគមន៍នេសាទអន្លង់ថ្មបាំង | ៥០១ | - ព្រៃលិចទឹកចម្រុះ | - ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារៈប្រយោជន៍ព្រៃលិចទឹក<br>- ដាក់ស្លាកហាមកាប់ព្រៃលិចទឹក<br>- ថែរក្សា ការពារព្រៃលិចទឹកចម្រុះ<br>- ចុះល្បាតការពារជាប្រចាំ | ៥០០ | ២០២០ | ២០២២ |

### ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ

### ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| បង្កើតក្រុមសន្សំប្រាក់១ក្រុម មានសមាជិក១៥នាក់ | - ផ្សព្វផ្សាយទស្សនៈក្រុមសន្សំ<br>- បោះឆ្នោតជ្រើសរើសគណៈកម្មការគ្រប់គ្រង<br>- បង្កើតគោលការណ៍របស់ក្រុមសន្សំប្រាក់<br>- ត្រួតពិនិត្យតាមដាន | ១.៥០០ | ២០២០ | ២០២២ |
| ៥០គ្រួសារចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | - ប្រជុំផ្សព្វផ្សាយ ជ្រើសរើសគ្រួសារកសិករ<br>- រៀបចំទ្រុងសម្រាប់ចិញ្ចឹម<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>- រកទិញពូជ និងដាក់ពូជចិញ្ចឹម<br>- តាមដានត្រួតពិនិត្យការថែទាំ | ១៥.០០០ | ២០២០ | ២០២២ |
| ៥០គ្រួសារចិញ្ចឹមជ្រូកតាម | - ប្រជុំផ្សព្វផ្សាយ ជ្រើសរើសគ្រួសារកសិករ | ៧.៥០០ | ២០២០ | ២០២២ |

| | | | | |
|---|---|---|---|---|
| បច្ចេកទេសជាលក្ខណៈគ្រួសារ | - រៀបចំទ្រុងសម្រាប់ចិញ្ចឹម<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>- រកទិញពូជ និងដាក់ពូជចិញ្ចឹម<br>- តាមដានត្រួតពិនិត្យការថែទាំ | | | |
| ១៥គ្រួសារចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | - ប្រជុំផ្សព្វផ្សាយ ជ្រើសរើសគ្រួសារកសិករ<br>- រៀបចំក្រោលគោសម្រាប់ចិញ្ចឹម<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>- តាមដានត្រួតពិនិត្យការថែទាំ | ៣០០x១៥=៤.៥០០ | ២០២០ | ២០២២ |
| ៧៥គ្រួសារដាំបន្លែតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | - ប្រជុំផ្សព្វផ្សាយ ជ្រើសរើសគ្រួសារកសិករ<br>- រៀបចំថ្នាលសម្រាប់បណ្តុះនិងដាំ<br>- បណ្តុះបណ្តាលបច្ចេកទេសដាំ<br>- តាមដានត្រួតពិនិត្យការថែទាំ | ២២.៥០០ | ២០២០ | ២០២២ |

### ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | បរិមាណកូនត្រី | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | បញ្ចប់ |
| ចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាមបច្ចេកទេសលក្ខណៈគ្រួសារ៣០គ្រួសារ | - ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>- រៀបចំស្រះ ដាក់កូនត្រី<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី<br>- ត្រួតពិនិត្យ ធ្វើសំណាក | ៥ស្រះ ទំហំ ៥ម×១០ម | ៤៥.០០០ ក្បាល/៣០ គ្រួសារ | ៩.០០០ | ២០២០ | ២០២២ |

### ឃ.២.៣.ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| ជួសជុលផ្លូវមួយខ្សែពីឃេក្រោមទៅឃេលើចំនួន១ខ្សែ | ១០.០០០ | ២០២០ | ២០២២ |
| សាងសង់លូកាត់ផ្លូវ១៥កន្លែង | ១០.០០០ | ២០២០ | ២០២២ |
| សាងសង់បង្គន់អនាម័យ៥០គ្រួសារ | ៧.៥០០ | ២០២០ | ២០២២ |
| បង្កើតឡជីវឧស្ម័ន០៥ គ្រួសារ | ៥.០០០ | ២០២០ | ២០២២ |
| ផ្តល់ធុងចម្រោះទឹក ៥០គ្រួសារ | ២.៥០០ | ២០២០ | ២០២២ |
| សាងសង់អណ្តូងស្នប់ ៣០កន្លែង | ១០.០០០ | ២០២០ | ២០២២ |

### ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ

ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ផែនការបង្ការ និងបន្សាំភាពធន់ការប្រែប្រួលអាកាសធាតុ | ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការបន្សាំ | ៧០០ | ២០២០ | ២០២២ |
| | រៀបចំបង្គោលវាស់កម្ពស់ទឹក | | | |
| | រៀបចំទីទួលសុវត្ថិភាព | | | |
| | ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិ | | | |

### ឃ.៣. ការងារគ្រប់គ្រង

### ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | តម្រូវការសម្ភារៈ | ចំនួន | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| សហគមន៍ចុះល្បាតដោយខ្លួនឯង | | ៦ដង/ខែ | ៥.២០០ | ២០២០ | ២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | | ៤ដង/ខែ | | ២០២០ | ២០២២ |
| ប្រេងសម្រាប់ល្បាត | | ១៤០លីត្រ/ខែ | | ២០២០ | ២០២២ |
| សេវាជួសជុល ថែទាំទូក និងម៉ាស៊ីន | | ២ ដង/ឆ្នាំ | | ២០២០ | ២០២២ |
| ផ្តល់សម្ភារល្បាត (១ ឈុត) | អាវពោង | ៧ អាវ | ១.០០០ | ២០២០ | ២០២២ |
| | អាវភ្លៀង | ៧ អាវ | | | |
| | គោមបំភ្លឺពាក់ក្បាល | ៧គោម | | | |
| | វិទ្យុទាក់ទង | ៣ គ្រឿង | | | |
| | កែវយឺត | ២ គ្រឿង | | | |
| | ម៉ាស៊ីនថត | ២គ្រឿង | | | |
| | អង្រឹង | ៧ អង្រឹង | | | |
| | តង់គ្របទូក(៤x៦) | ២ តង់ | | | |
| | ស្លាបចក្រ | ៤ គ្រឿង | | | |
| | សោរសម្រាប់ជួសជុលទូក | ២ សម្រាប់ | | | |
| | សោរច្រវាក់ចាក់ទូក | ២ សោរ | | | |
| | ឯកសណ្ឋាន១កំប្លេរ | ៧ កំប្លេរ | | | |

| សកម្មភាព | តម្រូវការសម្ភារៈ | ចំនួន | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ទិញទូកស្ទាច់ម៉ាស៊ីន (តូចមួយ ធំមួយ) | (២០-២៧ សេះ) | ២ គ្រឿង | ៣.០០០ | ២០២០ | ២០២២ |
| សាងសង់ទីស្នាក់ការសហគមន៍ | នៅចំណុចប៉ុស្តចាស់ (ដីគណៈកម្មការ) | ១ កន្លែង | ៣.០០០ | ២០២០ | ២០២២ |

### ឃ.៣.២.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១២ដង/ឆ្នាំ | ៤៤០ | ២០២០ | ២០២២ | |
| ចូលរួមប្រជុំប្រចាំខែ ឬត្រីមាស ជាមួយក្រុមប្រឹក្សាឃុំ | ១២ដង/ឆ្នាំ | ៣៦០ | | | |
| បណ្តុះបណ្តាលការរៀបចំរបាយការណ៍ កំណត់ហេតុ | ១ដង/ឆ្នាំ | ២៥០ | | | |
| បណ្តុះបណ្តាលការគ្រប់គ្រងថវិការ | ១ដង/ឆ្នាំ | ២៥០ | | | |
| បណ្តុះបណ្តាលសរសេរគម្រោងសំណើរ | ១ដង/ឆ្នាំ | ២៥០ | | | |
| ទស្សនៈកិច្ចសិក្សាក្រៅខេត្តក្រៅប្រទេស | ១ដង/ឆ្នាំ | ១.០០០ | | | |

### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួនដង | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ | ២/១ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | ២/១ឆ្នាំ | ៦០០ | | |
| ច្បាប់ជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | ២/១ឆ្នាំ | ៦០០ | | |
| ផ្សព្វផ្សាយដល់សមាជិកពីការប្រមូលប្រាក់បដិភាគ | ១/១ឆ្នាំ | ២០០ | | |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងពីសារៈប្រយោជន៍ធនធានជលផល | ១/១ឆ្នាំ | ២០០ | | |
| យុទ្ធនាការប្រមូលឧបករណ៍នេសាទខុសច្បាប់ | ១/១ឆ្នាំ | ១៥០ | | |

### ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈកិច្ចប្រជុំ និងមហាសន្និបាតប្រចាំឆ្នាំ | ៣០០ | ២០២០ | ២០២២ | - គណៈកម្មការសហគមន៍នេសាទ<br>- អាជ្ញាធរឃុំ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | | ២០២០ | ២០២២ | |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ប្រមូលភាគទានពីសមាជិកអ្នកដែលគ្រប់អាយុ១៨ឆ្នាំឡើង | ២០២០ | ២០២២ | ៤៨ | |
| ភាគទានប្រចាំឆ្នាំពីសមាជិក | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | ២០២០ | ២០២២ | ២២៥ | |
| ភាគទានពីអ្នកនេសាទក្រៅសហគមន៍ | ប្រមូលប្រាក់ភាគទានពីអ្នកនេសាទខាងក្រៅចំនួន៤០នាក់(៥០.០០០រៀល/ទូក/រដូវនេសាទ) | ២០២០ | ២០២២ | ១.៨៧៥ | |
| | ប្រមូលប្រាក់អ្នកមិនមែនជាសមាជិកសហគមន៍នេសាចំនួន៣៥នាក់ (៥០.០០០រៀល/ទូក/រដូវនេសាទ) | ២០២០ | ២០២២ | ១.៣១២ | |
| ភាគលាភពីក្រុមសន្សំប្រាក់ | ភាគលាភប្រចាំឆ្នាំរបស់ក្រុមសន្សំ | ២០២០ | ២០២២ | ៧៥ | |
| បដិភាគពីសេវាទេសចរណ៍សហគមន៍ | ស្នើបដិភាគថវិកាពីសេវាទេសចរណ៍សហគមន៍ | ២០២០ | ២០២២ | ៩០ | |
| **សរុបថវិកាដែលសហគមន៍មាន** | | | | ៥.៧៧៣ | |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល សប្បុរសជន) | • បញ្ចូលផែនការអភិវឌ្ឍសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ<br>• ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>• សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | ២០២០ | ២០២២ | ៣៧.៨៨៥ | |
| **សរុបថវិកាគ្រោងចំណាយ** | | | | ១២៤.៨៩០ | |

## ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ប្រជុំផ្ទៃក្នុងប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ១២០ | ២០២០ | ២០២២ | -គណៈកម្មការសហគមន៍នេសាទ |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ | ៣០០ | ២០២០ | ២០២២ | -គណៈកម្មការសហគមន៍នេសាទ |

## ច.យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យយុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ
- ជ្រើសរើសស្ត្រីមេគ្រួសារ ជាសមាជិកចំនួនយ៉ាងតិច៧% ចូលរួមក្នុងសកម្មភាពទ្រទ្រង់ជីវភាពរស់នៅ
- អញ្ជើញស្ត្រីជាសមាជិកសហគមន៍នេសាទចូលរួមយ៉ាងតិច ៤០% ក្នុងការបណ្តុះបណ្តាល សិក្ខាសាលា និងសកម្មភាព ទ្រទ្រង់ជីវភាពរស់នៅ និងវារីវប្បកម្ម
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការចូលរួមក្នុងការសម្រេចចិត្តនានា

- លើកទឹកចិត្តស្ត្រីជាគណៈកម្មការមិនបោះបង់ចោលការងារ
- រៀបចំការប្រជុំឱ្យសមស្របនឹងពេលវេលារបស់ស្ត្រី ដែលមានលទ្ធភាពចូលរួម
- ជំរុញឱ្យមានស្ត្រីយ៉ាងតិច ២៥% ជាសមាជិកគណកម្មការសហគមន៍នេសាទ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អន្លង់ថ្មបាំង រយៈពេល ៣ ឆ្នាំ (២០២០ - ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.១.ធនធានជលផល និងអេកូឡូស៊ី | | | | | | | |
| ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតទំហំ ពេលវេលា និងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ២ដង ក្នុង១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ១ដង×១០០×២លើក×៣ឆ្នាំ=៦០០ | -សហគមន៍នេសាទ<br>-រដ្ឋបាលជលផល<br>-អង្គការដៃគូ | ២០២០ | ២០២២ | |
| ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | ផលិត និងបោះបង្គោលព្រំចំនួន៧បង្គោល តាមព្រំប្រទល់សហគមន៍នេសាទ | - បង្គោលចំនួន៧ ដើម ត្រូវបានផលិតនិងបានបោះតាមព្រំប្រទល់<br>- កាត់បន្ថយបាននូវទំនាស់ព្រំប្រទល់ | ៤.០០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | ដំឡើងផ្ទាំងប៉ាណូផែនទី និងរូបភាពផ្សព្វផ្សាយចំនួន២ផ្ទាំង | ផ្ទាំងប៉ាណូផែនទីចំនួន២ផ្ទាំងបានផលិត និងបានបោះនៅក្នុងសហគមន៍ | ៥០០ | | ២០២០ | ២០២២ | |
| | ផលិតស្លាកអប់រំចំនួន៣០ស្លាក | ស្លាក៣០បានផលិតនិងដាក់តាមសហគមន៍នេសាទ និងព្រៃលិចទឹក | ១២០ | | ២០២០ | ២០២២ | |
| ឃ.១.៣.ការកំណត់និងរៀបចំតំបន់អភិរក្សអន្លង់តាឃឹម (គោល ៤៦) | - ផ្សព្វផ្សាយពីកន្លែងអភិរក្ស<br>- បោះទង់សំគាល់ព្រំតំបន់អភិរក្ស<br>- ដាក់ផ្លាកសញ្ញានៅតំបន់អភិរក្ស<br>- ចុះល្បាតការពារជាប្រចាំ | - ត្រី និងសត្វគ្រប់ប្រភេទ នឹងសំបូរឡើងវិញនៅក្នុងតំបន់សហគមន៍<br>-ប្រជាជនយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស និងបានដឹងពីព្រំប្រទល់ | ៤០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| ឃ.១.៤.ផែនការគ្រប់គ្រង ការពារព្រៃលិចទឹក | - ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារៈប្រយោជន៍ព្រៃលិចទឹក<br>- ដាក់ស្លាកហាមកាប់ព្រៃលិចទឹក<br>- ថែរក្សាការពារព្រៃលិចទឹកចម្រុះ<br>- ចុះល្បាតការពារជាប្រចាំ | ព្រៃលិចទឹកកើនឡើងវិញ<br>ធនធានត្រីមានការកើនឡើងវិញ | ៥០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | |
| ឃ.២.១.ផែនការមុខរបរបង្កើនប្រាក់ចំណូល | បង្កើតក្រុមសន្សំប្រាក់១ក្រុមមានសមាជិក ១៥នាក់ | ក្រុមសន្សំដែលមានសមាជិក១៥នាក់ត្រូវ បានបង្កើតក្នុងសហគមន៍ | ១.៥០០ | -រដ្ឋបាលជលផល<br>-អង្គការដៃគូ | ២០២០ | ២០២២ | |
| | ចិញ្ចឹមមាន់តាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមមាន់ ចំនួន២០គ្រួសារ | ៣.០០០ | | ២០២០ | ២០២២ | |
| | ចិញ្ចឹមជ្រូកតាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមជ្រូកចំនួន២៥គ្រួសារ | ៦.០០០ | | ២០២០ | ២០២២ | |
| | ចិញ្ចឹមគោតាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមគោចំនួន១៥គ្រួសារ | ៤.៥០០ | | ២០២០ | ២០២២ | |
| | រៀបចំធនាគារក្របីក្នុងសហគមន៍ | មានសមាជិកចូលរួមចំនួន១៥គ្រួសារ | ៣.៣០០ | | ២០២០ | ២០២២ | |
| ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមត្រីអណ្តែងចំនួន៣០គ្រួសារ | ៩.០០០ | -រដ្ឋបាលជលផល<br>-អង្គការដៃគូ | ២០២០ | ២០២២ | |
| ឃ.២.៣.ផែនការសេវាសហគមន៍និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច | ជួសជុលផ្លូវមួយខ្សែក្នុងភូមិ | មានផ្លូវល្អមួយខ្សែក្នុងភូមិ | ១០.០០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | សាងសង់លូកាត់ផ្លូវ | មានលូកាត់ផ្លូវ១៥កន្លែងសាងសង់រួច | ១០.០០០ | | | | |
| | ខួងអណ្តូងស្នប់ទឹកស្អាត | មានអណ្តូងស្នប់ទឹកស្អាត៣០កន្លែង | ១០.០០០ | | | | |
| | សាងសង់បង្គន់អនាម័យ | មានបង្គន់អនាម័យចំនួន៣០ | ៧.៥០០ | | | | |
| | បង្កើតឡជីវឧស្ម័ន | មានសមាជិកចូលរួមចំនួន៥គ្រួសារ | ៥.០០០ | | ២០២០ | ២០២២ | |
| | ផ្តល់ធុងចម្រោះទឹក | មានធុងចម្រោះទឹកចំនួន៥០ធុង | ១.៥០០ | | ២០២០ | ២០២២ | |
| ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ | ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការបង្ការ | គណៈកម្មការ និងសមាជិកមានការយល់ដឹងពីផលប៉ះពាល់ពីការប្រែប្រួលអាកាស ធាតុ និងរបៀបបង្ការ | ៣០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | រៀបចំបង្គោលវាស់កម្ពស់ទឹក | មានបង្គោលវាស់កំពល់ទឹកចំនួន១ | ២០០ | | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | រៀបចំទីទួលសុវត្ថភាព | មានទីទួលសុវត្ថភាពមួយកន្លែង | ១០០ | | ២០២០ | ២០២២ | |
| | ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយនៅក្នុងភូមិ | មានគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងភូមិ | ១០០ | | ២០២០ | ២០២២ | |
| **ឃ.៣. ការងារគ្រប់គ្រង** | | | | | | | |
| ឃ.៣.១.ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស | សហគមន៍ចុះល្បាតដោយខ្លួនឯង | បានចុះល្បាត៣ដង/ខែ | ៥.២០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | បានចុះល្បាត២ដង/១ខែសហការជាមួយអាជ្ញាធរមូលដ្ឋាន | | | ២០២០ | ២០២២ | |
| | ប្រេងសម្រាប់ចុះល្បាត | | | | ២០២០ | ២០២២ | |
| | សេវាជួសជុលទូក និងម៉ាស៊ីន | | | | ២០២០ | ២០២២ | |
| | ផ្តល់សម្ភារល្បាត | សម្ភារៈ១ឈុត | ១.០០០ | | ២០២០ | ២០២២ | |
| | ទិញទូកស្ពាច់ម៉ាស៊ីន (១៣សេះ) | មានទូកម៉ាស៊ីន ចំនួន១គ្រឿង | ១.២០០ | | ២០២០ | ២០២២ | |
| | សាងសង់ទីស្នាក់ការសហគមន៍ | មានស្នាក់ការ១ខ្នងសម្រាប់សហគមន៍នេសាទធ្វើការងារ | ៦៥០ | | ២០២០ | ២០២២ | |
| ឃ.៣.២. ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | បានប្រជុំ១ដង/១ខែ ជាមួយគណៈកម្មការ សមាជិក | ៤៤០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-អាជ្ញាធរឃុំ<br>-សហគមន៍នេសាទ | ២០២០ | ២០២២ | |
| | ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ចូលរួម១ដង/១ខែជាមួយក្រុមប្រឹក្សាឃុំ | ៣៦០ | | ២០២០ | ២០២២ | |
| | បណ្តុះបណ្តាលការរៀបចំរបាយការណ៍ កំណត់ហេតុ | -មានវគ្គបណ្តុះបណ្តាលលើមុខជំនាញនីមួយៗ១លើក/១ឆ្នាំ | ២៥០ | | ២០២០ | ២០២២ | |
| | បណ្តុះបណ្តាលអំពីការគ្រប់គ្រងថវិកា | -សមត្ថភាពសហគមន៍នេសាទបានល្អ | ២៥០ | | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | បណ្តុះបណ្តាលសរសេរគម្រោងសំណើរ | -គណៈកម្មការសហគមន៍នេសាទអាចអនុវត្តន៍បាន | ២៥០ | | ២០២០ | ២០២២ | |
| | ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | -បានទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍១លើក/១ឆ្នាំ<br>-បានទទួលនូវបទពិសោធន៍ល្អៗ | ១.០០០ | | ២០២០ | ២០២២ | |
| ឃ.៣.៣.បង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-អាជ្ញាធរឃុំ<br>-សហគមន៍នេសាទ | ២០២០ | ២០២២ | |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | | ២០២០ | ២០២២ | |
| | ផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | | ២០២០ | ២០២២ | |
| | ផ្សព្វផ្សាយដល់សមាជិកពីការប្រមូលប្រាក់បដិភាគ | បានរៀបចំផ្សព្វផ្សាយ១ដង/ឆ្នាំ | ២០០ | | ២០២០ | ២០២២ | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងពីសារៈប្រយោជន៍ធនធានជលផល | បានរៀបចំយុទ្ធនាការ១ដង/ឆ្នាំ | ២០០ | | ២០២០ | ២០២២ | |
| | យុទ្ធនាការប្រមូលឧបករណ៍នេសាទខុសច្បាប់នៅក្នុងសហគមន៍ | បានរៀបចំយុទ្ធនាការ១ដង/ឆ្នាំ | ១៥០ | | ២០២០ | ២០២២ | |
| ឃ.៣.៤.ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | -បានផ្សព្វផ្សាយ ២ដង/ឆ្នាំ<br>-បានបញ្ចូលសកម្មភាពផែនការគ្រប់គ្រងរបស់សហគមន៍នេសាទទៅក្នុងផែនការកម្មវិធីវិនិយោគឃុំ | ៣០០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-អាជ្ញាធរឃុំ | ២០២០ | ២០២២ | |
| | បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទ | | | | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | សហគមន៍ទៅក្នុងកម្មវិធីវិនិយោគឃុំ | | | | | | |
| ឃ.៣.៥.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ | ភាគទានពីសមាជិកភាព | សមាជិកសហគមន៍បានបង់ភាគទានសមាជិកភាព | | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-អាជ្ញាធរឃុំ<br>-សហគមន៍នេសាទ | ២០២០ | ២០២២ | |
| | ភាគទានពីសមាជិកប្រចាំឆ្នាំ | សមាជិកសហគមន៍បានបង់ភាគទានប្រចាំឆ្នាំ១ឆ្នាំម្តង | | | ២០២០ | ២០២២ | |
| | ភាគទានពីអ្នកខាងក្រៅ និងអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | បានទទួលប្រាក់បដិភាគពីអ្នកនេសាទមកពីខាងក្រៅ | | | ២០២០ | ២០២២ | |
| | | បានទទួលប្រាក់បដិភាគពីអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ | | | | | |
| | ភាគលាភពីក្រុមសន្សំប្រាក់ | ស្មើបដិភាគថវិកាពីក្រុមសន្សំប្រាក់ | | | ២០២០ | ២០២២ | |
| | បដិភាគពីសេវាទេសចរណ៍សហគមន៍ | ស្មើបដិភាគថវិកាពីសេវាទេសចរណ៍សហគមន៍ | | | | | |
| | ប្រាក់ចំណូលពីប្រភពផ្សេងៗ(ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជន) | សហគន៍នេសាទទទួលបានកញ្ចប់ថវិកាពីប្រភពស្របច្បាប់ផ្សេងៗ | | | ២០២០ | ២០២២ | |
| ង.ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ | ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | -បានប្រជុំ៤ត្រីមាស/១ឆ្នាំ<br>-ទទួលបានរបាយការណ៍និងការវាយតម្លៃ | ១២០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-អាជ្ញាធរឃុំ | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
|  | រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំដោយមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ និងស្ត្រី | -បានប្រជុំមហាសន្និបាត ១ដង/ឆ្នាំ<br>-ធ្វើសេចក្តីរាយការណ៍ពីលទ្ធផលការងារ និងលើកផែនការបន្ត | ៣០០ | -សហគមន៍នេសាទ | ២០២០ | ២០២២ |  |

## តារាងកម្មវិធីការងារប្រចាំឆ្នាំរយៈពេល៣ឆ្នាំ ២០២០ - ២០២២

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ឃ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា និងទីកន្លែងនេសាទ និងប្រភេទឧបករណ៍នេសាទហាមឃាត់ | | | | | × | | | | | | × | | | | | | × | | | | | | × | | | | | | × | | | | | | | |
| ឃ.១.២. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផលិតបង្គោលព្រំឭបង្គោល | | | | | | × | × | × | × | | | | | | | | | | | | | | | | | | | | | | | | | | | |
| តម្លើងផ្ទាំងប៉ាណូផែនទីចំនួន២ផ្ទាំង | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផលិតស្លាកអប់រំចំនួន៣០ | | | | | | | | | | | | | × | × | × | | | | | | | | | | | | | | | | | | | | | |
| ឃ.១.៣.ផែនការកំណត់ និងរៀបចំតំបន់អភិរក្សអន្លង់តាឃឹម (គោល៤៦) | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងសារៈប្រយោជន៍ | | | | | | × | | | | | | × | | | | | | × | | | | | | × | | | | | | × | | | | | | |
| ដាក់ទង់សម្គាល់កន្លែងអភិរក្ស និងដាក់ស្លាកសញ្ញា | | | | | | | | | | | | × | | | | | | | | | | | | | | | | | | | | | | | | |
| ដាក់ផ្លាកសញ្ញានៅតំបន់ | | | | | | | | | | × | | | | | | | | | | | | | | | | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| អភិរក្ស១០ស្លាក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចុះល្បាតការពារជាប្រចាំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| **ឃ.១.៤. ផែនការគ្រប់គ្រង ការពារព្រៃលិចទឹក** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយអោយបានទូលំទូលាយពីសារៈប្រយោជន៍ | | | | | × | | | | | | | | × | | | | | | × | | | | | | × | | | | | × | | | | | | |
| ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក | | | | | | | | × | × | × | | | | | | | | | | | | | | | | | | | | | | | | | | |
| ចុះល្បាតការពារជាប្រចាំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| **ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បង្កើតក្រុមសន្សំប្រាក់១ក្រុមមានសមាជិក ១៥នាក់ | | | | | | × | × | × | × | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមត្រីតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | | | | | × | × | | | | | | | | | | | × | × | | | | | | | | | | | × | × | | | | | | |
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | | | | | | × | × | | | | | | | | | | | × | × | | | | | | | | | | | × | × | | | | | |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | | | | | | × | × | | | | | | | | | | | × | × | | | | | | | | | | | × | × | | | | | |
| ចិញ្ចឹមគោតាមបច្ចេកទេស | | | | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ជាលក្ខណៈគ្រួសារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាំបន្លែតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | | | | | | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| **ឃ.២.២. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ជួសជុលផ្លូវមួយខ្សែក្នុងភូមិ | | | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| សាងសង់លូកាត់ផ្លូវ | | | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ខួងអណ្តូងស្នប់ទឹកស្អាត | | | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| សាងសង់បង្គន់អនាម័យ | | | | | | | × | × | × | × | × | × | | | | | | | | | | | | | | | × | × | × | × | × | | | | | |
| បង្កើតឡជីវឧស្ម័ន | | | | | | | | | | | | | | × | × | × | × | × | × | | | | | | | | | | | | | | × | × | × | × |
| ផ្តល់ធុងចម្រោះទឹក | | | | | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.២.៣.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួល អាកាសធាតុ និងការបង្ការផ្សេងៗ | | | × | × | × | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំបង្គោលវាស់កម្ពស់ទឹក | | | | | | | | | | × | × | × | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំទីទួលសុវត្ថភាព | | | | | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | |
| ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយនៅក្នុងភូមិ | | | | | | × | × | × | | | | | | | | | | | × | × | × | | | | | | | | | | × | × | × | | | |
| **ឃ.៣. ការងារគ្រប់គ្រង** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សហគមន៍ចុះល្បាតដោយខ្លួនឯង | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ទិញសម្ភារល្បាត | | | × | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ទិញទូកស្នាច់ម៉ាស៊ីន | | | | | × | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សាងសង់ទីស្នាក់ការសហគមន៍នេសាទ | | | | | | × | × | × | × | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.២. ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| បណ្ដុះបណ្ដាលការរៀបចំរបាយការណ៍ កំណត់ហេតុ | | | | | | | | × | | | | | | | | | | | | | | | | × | | | | | | | | | × | | | |
| បណ្ដុះបណ្ដាលអំពីការគ្រប់គ្រងថវិកា | | | | | | | | | | | × | | | | | | | | | | | | | | | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| បណ្តុះបណ្តាលសរសេរគម្រោងសំណើរថវិកា | | | | | | | x | | | | | | | | | | | | | | | | | | x | | | | | | | | | | | |
| ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | | | | | | | | | | | | | x | | | | | | | | | | | | | | | | | | | | | | | |
| ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | | | x | | | | | x | | | | | | x | | | | | | x | | | | | | | x | | | | | | x | | | |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | | | x | | | | | x | | | | | | x | | | | | | x | | | | | | | x | | | | | | x | | | |
| ផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | | | | | | | x | | | | | | | | | | | | | x | | | | | | | | | | x | | | | | | |
| ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | | | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | | | | | | | x | | | | | | | | | | | | | x | | | | | | | | | | x | | | | | | |
| យុទ្ធនាការប្រមូលឧបករណ៍នេសាទខុសច្បាប់ | x | | | | | | | x | | | | | | x | | | | | | x | | | | | | | x | | | | | | x | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន សន្និបាតប្រចាំឆ្នាំ | | | × | | | | | | | | | × | | | | | | | | | × | | | | | | | | × | | | | | | | |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងកម្មវិធីវិនិយោគឃុំ | | | | | | × | × | × | | | | | | | | | | | × | × | × | | | | | | | | | × | × | × | | | | |
| **ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ភាគទានពីសមាជិកសហគមន៍នេសាទ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ភាគទានប្រចាំឆ្នាំតាមគ្រួសារ | | | | × | | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | |
| ភាគទានពីអ្នកនេសាទខាងក្រៅ និងអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ភាគលាភពីក្រុមសន្សំប្រាក់ | | | | | | | | | × | × | | | | | | | | | | | × | × | | | | | | | | | | | × | × | | |
| ចំណូលពីសេវាទេសចរណ៍ | | | | × | × | | | | | | | | | | | | × | × | | | | | | | | | | × | × | | | | | | | |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ការមិនមែន រដ្ឋាភិបាល និង អំណោយពីសប្បុរសជន) | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំផ្ទៃក្នុងប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | | | × | | | × | | | × | | | × | | | × | | | × | | | × | | | × | | | × | | | × | | | × | | | × |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពី អ្នកពាក់ព័ន្ធ | | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | | | | | × |

លេខ ២៧ ស.ន
បានឃើញ និងបញ្ជូនមក
លោកនាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង
" ដើម្បីពិនិត្យ និងសម្រួល "
ថ្ងៃ.................ខែ.............ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ស្ទឹងត្រែង,ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១៩
នាយផ្នែករដ្ឋបាលជលផលសេកុង

លេខ ១៣៤/១៩
បានឃើញ និងបញ្ជូនមក
លោកនាយផ្នែករដ្ឋបាលជលផលសេកុង
" ដើម្បីជូនពិនិត្យ និងសម្រួល "
ថ្ងៃ.................ខែ.............ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
សង្កាត់សាមគ្គី,ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១៩
ចៅសង្កាត់សាមគ្គី

ជា ម៉ាលី

សូមគោរពជូន
លោកចៅសង្កាត់សាមគ្គី
" ដើម្បីជូនពិនិត្យ និងសម្រួល "
ថ្ងៃ.................ខែ.............ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ភូមិខាំផាន់(ចំនុចខេ),ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ២០១៩
ប្រធានគណៈកម្មការសហគមន៍នេសាទអន្លង់ថ្មបាំង

លេខ.......................

បានឃើញ និងគោរពជូន

លោកប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង

" ដើម្បីជូនពិនិត្យ និងសម្រួល "

ថ្ងៃ.............ខែ...........ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ស្ទឹងត្រែង,ថ្ងៃទី......១៧......ខែ......១......ឆ្នាំ២០១៩

ន.នាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង

---

លេខ.......................

បានឃើញ និងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ "

ថ្ងៃ.............ខែ...........ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ស្ទឹងត្រែង,ថ្ងៃទី......២៣......ខែ......១......ឆ្នាំ២០១៩

ប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង

លៀង_សេង

---

លេខ......១៧៥ ៤.៨

បានឃើញ និងឯកភាព

ថ្ងៃ.............ខែ...........ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ,ថ្ងៃទី......១៧......ខែ.............ឆ្នាំ២០២០

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

អេង ជាសាន